ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ជម្ងឺសារទឹក



នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ASDP, ADB
Loan 2022-CAM(SF)
ឆ្នាំ2010

# ជម្ងឺសារទឹក

## Haemorrhagic Septicemia (HS) (Pasteurellosis)

### ១-និយមន័យៈ

ជំងឺសារទឹក ជាជំងឺឆ្លងរាតត្បាតយ៉ាងសាហាវមួយ ក្នុងចំណោមជំងឺឆ្លងនានា ។ បង្កឡើងដោយបាក់តេរីប៉ាស្ទ័ររ៉ែលឡាម៉ុលតូសីដា (Pasteurella Multocida ) បាក់តេរីនេះមានរាងជាកូនដំបងខ្លី គ្មានចលនា និងគ្មានស្ព័រ ។ កើតឡើងលើសត្វគ្រប់ប្រភេទដូចជាគោ–ក្របី ចៀម ពពែ ជ្រូក ។ល។ បណ្តាលឱ្យមានការលាក និងដាំឈាមនៅតាមសរីរាង្គខាងក្នុងរបស់សត្វ ជាពិសេសប្រដាប់ដកដង្ហើម និងប្រដាប់រំលាយអាហារ ។ ជំងឺនេះច្រើនកើតមាននៅតំបន់ទំនាប សើមជោគជាំដក់ទឹក ពិសេសកើតមាននាដើមរដូវភ្លៀង ។ ជំងឺនេះបណ្តាលឱ្យគោ–ក្របី ងាប់យ៉ាងឆាប់រហ័ស ។ សត្វដែលឆាប់ទទួលជំងឺនេះជាងគេ គឺក្របី ជាពិសេសចំពោះសត្វក្មេងអាចទទួលជំងឺនេះយ៉ាងឆាប់រហ័ស។

ជំងឺនេះកើតមានឡើងជារៀងរាល់ឆ្នាំនៅប្រទេសកម្ពុជា ។ នៅឆ្នាំ២០០៨ ជំងឺសារទឹកបានកើតនៅក្នុងខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា